# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:.៣៧..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការលុប និងកាត់បន្ថយដែនទេសាទបន្ថែមទៀតក្នុងនាទីឡូត៍នេសាទ ខេត្តកណ្តាល ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស /៩៤ / ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣ ក្រច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ . បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ ២០០១ ស្តីពីការលុបនាទីឡូត៍នេសាទនិងកាត់បន្ថយដែននេសាទក្នុងនាទីឡូត៍នេសាទខេត្តកណ្តាល ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ
- បានទទួលការឯកភាពពីសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០០៣

## សម្រេច

**មាត្រា១ .-**

ត្រូវបានលុបចេញនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទបន្ថែមទៀតក្នុងនាទីឡូត៍នេសាទខេត្តកណ្តាលទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារមានដូចខាងក្រោម :

១-លុបឡូត៍នេសាទឆ្នេរខ្សាច់ លេខ ០១ ចេញពីនាទីឡូត៍នេសាទចាប់ពីរដូវនេសាទ ឆ្នាំ ២០០៣-២០០៤ តទៅ ។

២-កាត់ចេញពីនាទីឡូត៍នេសាទនៃផ្ទៃដែននេសាទក្នុងខេត្តកណ្តាល និងកំណត់ព្រំប្រទល់ឡូត៍នេសាទជាថ្មីចាប់ពីពេលនេះតទៅ ៖

-ឡូត៍នេសាទបឹងព្រែក លេខ ០១ ត្រូវកាត់ចេញ ២៦ ហ.ត

-ឡូត៍នេសាទលេខ ០៨ ត្រូវកាត់ចេញ ១៤២ ហ.ត

-ឡូត៍នេសាទ លេខ ០៩ ត្រូវកាត់ចេញ ៥៩ ហ.ត

-ឡូត៍នេសាទ លេខ ១៨ ត្រូវកាត់ចេញ ១.៨៦៨ ហ.ត ។

៣-ឡូត៍នេសាទ លេខ ០៨ និង ឡូត៍នេសាទលេខ ០៩ ត្រូវបានបញ្ចូលគ្នារៀបចំផែនទីឡូត៍នេសាទលេខ ០៩ ថ្មី ។ តារាង និងផែនទីភ្ជាប់ជាមួយ ឧបសម្ព័ន្ធ។

**មាត្រា២ .-**

ដែននេសាទដែលបានលុបចោលនិងកាត់ចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូនប្រជាពលរដ្ឋប្រកបរបរនេសាទជាលក្ខណៈគ្រួសារ ។

ហាមដាច់ខាតមិនឱ្យបុគ្គលណាមួយហ៊ុំព័ទ្ធយកទៅលក់ឬជួលធ្វើអាជីវកម្មផ្តាច់មុខឡើយ ។

**មាត្រា៣ .-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទដើម្បីគ្រប់គ្រងដែននេសាទដែលបានលុប និងកាត់ចេញពីនាទីឡូត៍នេសាទនេះ ។

**មាត្រា៤ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៥

-ឯកសារ-កាលប្បវត្តិ


ផែនទី ឡូត៍នេសាទលេខ ០១ ខេត្តកណ្ដាល
សំរាប់ភ្ជាប់ជាមួយអនុក្រឹត្យ លេខ.៧៦..អនក្រ.បក ចុះថ្ងៃទី.២៦...ខែ.វិច្ឆិកា ឆ្នាំ ២០០៣
រៀបចំដោយការិយាល័យកិច្ចការដែននេសាទ និងផ្សព្វផ្សាយ
នាយកដ្ឋានជលផល
TONLE BASAK (BASSAC)
៦.៣៤៨ ហ.ត
២.៤២៤ ហ.ត
០១
០២
០៣
កំណត់សំគាល់
ព្រំប្រទល់ស្រុក
ផ្លូវលំ
ទន្លេ-ស្ទឹង-ព្រែក
របាំងឬស្ស
ព្រៃស្មោក
ស្រែ-ទំនាប់បឹង
បឹង-ត្រពាំង
ព្រៃលិចទឹក
ព្រំប្រទល់ឡូត៍នេសាទ ( ២.៤២៤ ហ.ត )
ដែននេសាទសំរាប់ប្រជាពលរដ្ឋ ( ៦.៣៤៨ ហ.ត )
មាត្រដ្ឋាន ១:៥០ ០០០

៦

# ផែនទី ឡូត៍នេសាទលេខ ០៨ និង ០៩ ខេត្តកណ្តាល ដែលបានកាត់បន្ថែម

រៀបចំដោយការិយាល័យកិច្ចការដែននេសាទ និងផ្សព្វផ្សាយ
នាយកដ្ឋានជលផល



# ផែនទី ឡូត៍នេសាទលេខ ០៩ ខេត្តកណ្តាល

សំរាប់ភ្ជាប់ជាមួយអនុក្រឹត្យ លេខ៧៦.....អនក្រ.បក ចុះថ្ងៃទី២៦....ខែវិច្ឆិកា.ឆ្នាំ ២០០៣

រៀបចំដោយការិយាល័យកិច្ចការផែនទេសាទ និងផ្សព្វផ្សាយ
នាយកដ្ឋានជលផល



**តំណាងសំគាល់**

- ព្រំប្រទល់ស្រុក
- ផ្លូវលំ
- ទន្លេ-ស្ទឹង-ព្រែក
- របាំងឆ្នូស
- ស្រែ-ទំនាប់បឹង
- បឹង-ត្រពាំង
- ព្រៃលិចទឹក
- ព្រៃកម្ពោត
- ព្រំប្រទល់ឡូត៍នេសាទ (២.៩៥៩ ហ.ត)
- ដែននេសាទសំរាប់ប្រជាពលរដ្ឋ (៦.៦០៥ ហ.ត)

ជ ខ ត ន

មាត្រដ្ឋាន ១:៥០.០០០



